**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា

******

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ ÷**

បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល រៀបចំ និងសម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង ដែលមានសមាសភាពដូចខាងក្រោម÷

www.pheakdeylaw.com

| | | |
|---|---|---|
| ១- ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ប្រធាន |
| ២- ឯកឧត្តម **ក្រាក់ ហាម** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ ចិន្តា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **សួស គង់** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម **ម៉ឹង សំផន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦- ឯកឧត្តម **ទី ចន្ទ្រផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៧- ឯកឧត្តម **ឌឹក គ្រឿនទុត្ថា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- ឯកឧត្តម **ជួ យិនស៊ឹម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៩- ឯកឧត្តម **ខ្ទិម គឹមសឺរ៉ា** | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ១០- ឯកឧត្តម **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១- ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២- ឯកឧត្តម **ឈី សន់** | អនុរដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៣- ឯកឧត្តម **ទឡើ ចិសុទ្ធ** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤- ឯកឧត្តម **ទី សុគន្ធ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធាន រដ្ឋបាលព្រៃឈើ | សមាជិក |
| ១៥- ឯកឧត្តមឧត្តមសេនីយ៍ឯក **គឹម ចិនខាន** | នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងជានាយរងសេនាធិការចំរុះនៃអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **ពេជ្រ ជីវ័ន** | ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៧- ឯកឧត្តម **ហោង រតនា** | អគ្គនាយកមជ្ឈមណ្ឌលបោសសំអាតមីនកម្ពុជា | សមាជិក |
| ១៨- ឯកឧត្តម **អ៊ី ឈាន** | អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន | សមាជិក |
| ១៩- ឯកឧត្តម **អ៊ុំ ម៉ារ៉ា** | អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ | សមាជិក |
| ២០- ឯកឧត្តម **ពិច សុខិន** | អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| ២១- ឯកឧត្តម **អ៊ុង អឿន** | អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |

**ប្រការ ២ ÷**

គណៈកម្មការអន្តរក្រសួង មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការរៀបចំ និងសម្របសម្រួលការអនុវត្តគោលនយោបាយ ផែនការ និងគម្រោងអភិវឌ្ឍការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង ក្នុងលក្ខណៈជាប្រព័ន្ធ និងជាខ្សែសង្វាក់ប្រទាក់ក្រឡាគ្នា។

www.pheakdeylaw.com

គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម÷

- រៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍន៍ជាកញ្ចប់ សម្រាប់ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង នៃព្រះរាជាណាចក្រកម្ពុជា ឱ្យស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- រៀបចំគម្រោង និងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្របសម្រាប់ធ្វើការអភិវឌ្ឍ នៅតាមបណ្តោយព្រំដែនទិសខាងលិច និងខាងជើង
- សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស
- ផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្ម័គ្រចិត្ត ទៅតាំងទីលំនៅនៅតំបន់ឱ្យបានច្រើនកុះករ
- ទាក់ទាញឱ្យមានការចូលរួមវិនិយោគពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោង។

**ប្រការ ៣ ÷**

គណៈកម្មការអន្តរក្រសួង ត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងតំណាងដៃគូអភិវឌ្ឍន៍ ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៤ ÷**

គណៈកម្មការអន្តរក្រសួង ត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។ ប្រធានគណៈកម្មការអន្តរក្រសួង អាចស្នើសុំមន្ត្រីពីក្រសួងស្ថាប័នពាក់ព័ន្ធឱ្យមកចូលរួមជាសមាជិកនៃលេខាធិការដ្ឋានតាមការចាំបាច់។

**ប្រការ ៥ ÷**

គណៈកម្មការអន្តរក្រសួងប្រើប្រាស់ត្រារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ ៦ ÷**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

www.pheakdeylaw.com

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសមាសភាពដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com